# នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត

នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត មានការិយាល័យចំណុះជាសេនាធិការចំនួន ០៦គឺៈ

១- ការិយាល័យរដ្ឋបាល
២- ការិយាល័យនីតិក្រម និងអាជ្ញាប័ណ្ណប្រត្តិបត្តិករ
៣- ការិយាល័យនិយ័តកម្មប្រព័ន្ធ
៤- ការិយាល័យនិយ័តកម្មសេដ្ឋកិច្ច
៥- ការិយាល័យកំរិតគុណភាព
៦- ការិយាល័យព័ត៌មានវិទ្យា និង DNS

នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត ទទួលបន្ទុកតាក់តែងនយោបាយរយៈពេលវែង កំណត់បញ្ជីតំលៃផ្សេងៗ រៀបចំ និងការតាមដានទំនាក់ទំនងអន្តរជាតិក្នុងវិស័យនេះ ជាពិសេសនាយកដ្ឋានត្រូវៈ

- កំណត់នយោបាយរបស់កម្ពុជាអំពីទូរគមនាគមន៍រយៈពេលវែងនិងតាក់តែងច្បាប់ស្តីអំពី ទូរគមនាគមន៍
- តាមដានពីការបោះទីតាំងអង្គភាពទូរស័ព្ទមូលដ្ឋានរបស់គ្រឹះស្ថានសាធារណៈទូរគមនាគមន៍ កម្ពុជា និងរបស់បណ្តាការីនៅតាមខេត្ត និងស្រុកនិមួយៗ
- រៀបចំរបាយការណ៍ប្រចាំខែរបស់ក្រសួងស្តីពីការរីកចំរើនរបស់អង្គភាពមូលដ្ឋានទាំងនោះ
- តាក់តែងបញ្ជីតំលៃផ្សេងៗ ដោយយកចិត្តទុកដាក់ពីទិដ្ឋភាពសង្គម និងតំបន់
- ជាតំណាងឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងការប្រជុំជាអន្តរជាតិស្តីពីបញ្ជីតំលៃជាទ្វេភាគី ពហុភាគីមានជាអាទិ៍ សហភាពទូរគមនាគមន៍អន្តរជាតិ
- ជាតំណាងឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៅក្នុងការប្រជុំអន្តរជាតិនានា
- សំរបសំរួលកិច្ចព្រមព្រៀងទ្វេភាគីក្នុងវិស័យទូរគមនាគមន៍

ទូរស័ព្ទទំនាក់ទំនងៈ ៨៥៥-២៣-៧២២៣៥០
ទូរសារលេខៈ ៨៥៥-២៣-៧២២៩៨១

ឯកសារយោងៈ អនុក្រឹត្យលេខ៦៦អនក្រ.បកចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧